# ឯកសារជំនួយស្មារតីស្តីពីព្រៃកោងកាង និងទិដ្ឋភាពយេនឌ័រនៅអាស៊ីៈ ករណីសិក្សានៅកម្ពុជា

ខែតុលា ឆ្នាំ២០២៤

## សារគន្លឹះ

- ជម្រើសក្នុងការចិញ្ចឹមជីវិតរបស់ស្ត្រីនៅតាមសហគមន៍នេសាទ នៅមានភាពរឹតត្បិតច្រើនជាងបុរស ដែលកត្តានេះធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានចំពោះភាពធន់នឹងអាកាសធាតុរបស់ស្ត្រី។ ដូច្នេះ ស្ត្រីនៅសហគមន៍នេសាទ ចាំបាច់គួរទទួលបានជំនួយក្នុងការបង្កើតជម្រើសក្នុងការចិញ្ចឹមជីវិតដែលអាចបង្កើតប្រាក់ចំណេញ ដើម្បីបំពេញតម្រូវការ និងចំណូលចិត្តរបស់ពួកគេ។
- ការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងសហគមន៍នេសាទនៅមានកម្រិត ដោយសារបទដ្ឋានសង្គម និងវប្បធម៌ ដែលនៅតែគាំទ្របុរសក្នុងភាពជាអ្នកដឹកនាំ។ ការធ្វើអន្តរាគមន៍ដោយបង្កើនការយល់ដឹងពីសមភាពយេនឌ័រ និងការកសាងចំណេះដឹងជាគោលដៅសម្រាប់ស្ត្រី អាចជួយលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងការគ្រប់គ្រងសហគមន៍នេសាទបាន ។
- ការលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងការគ្រប់គ្រងធនធានធម្មជាតិមានសារៈសំខាន់សម្រាប់ការការពារប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង ដូចដែលបានបង្ហាញតាមបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ លើគម្រោងគាំទ្រតួនាទីរបស់ស្ត្រីក្នុងការស្តារ និងអភិរក្សព្រៃកោងកាងជាដើម។
- **ឯកសារជំនួយស្មារតីនេះ ផ្តល់ព័ត៌មានបឋម ជាជំនួយស្មារតីដល់សមាជិក សមាជិកាសភាកម្ពុជា សម្រាប់ពេលចុះទៅបំពេញបេសកកម្ម ដើម្បីប្រមូលទិន្នន័យបន្ថែមពីឱកាស និងធនធានដែលជា សេចក្តីត្រូវការ ដើម្បីពង្រឹងសហគមន៍នេសាទ និងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង តាមរយៈគោលការណ៍លើកកម្ពស់សមភាពយេនឌ័រ។**

## សេចក្តីផ្តើម

សហគមន៍នេសាទនៅកម្ពុជាត្រូវបានបង្កើតឡើងជាកិច្ចអន្តរាគមន៍ ដើម្បីការពារប្រព័ន្ធអេកូឡូស៊ីក្នុងទឹកដោយផ្អែកលើសហគមន៍។ សារៈសំខាន់នៃសហគមន៍នេសាទគឺ ជម្រុញឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការស្តារឡើងវិញនូវព្រៃកោងកាង ការយល់ដឹងអំពីការអភិរក្សព្រៃកោងកាង និងការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។ គិតត្រឹមឆ្នាំ

២០១៨ កម្ពុជាមានសហគមន៍នេសាទសរុបចំនួន ៥១៦ ដែលរួមមានសហគមន៍នេសាទទឹកសាបចំនួន ៤៧៥ និងសហគមន៍នេសាទទឹកប្រៃចំនួន៤១ ជាមួយនឹងសមាជិកសរុបចំនួន ៣៣២ ១៦៨នាក់ ។

ទោះបីជាអនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមន៍នេសាទនៅកម្ពុជា លើកទឹកចិត្តដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រីក៏ដោយ ការស្រាវជ្រាវថ្មីៗបានបង្ហាញថា ការចូលរួមរបស់ស្ត្រីនៅមានកម្រិតនៅឡើយ។ កង្វះការចូលរួមរបស់ស្ត្រី គឺធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង ដោយក្នុងនោះ គេបានរកឃើញថា ការចូលរួមរបស់ស្ត្រីក្នុងអភិបាលកិច្ចព្រៃកោងកាង អាចកាត់បន្ថយភាពតានតឹងលើប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងបាន ហើយការបញ្ចូលចំណេះដឹងអេកូឡូស៊ីដោយបញ្ជ្រាបយេនឌ័រ អាចបង្កើនកិច្ចខិតខំប្រឹងប្រែងលើកិច្ចអភិរក្សព្រៃកោងកាងផងដែរ[1]។

ឯកសារជំនួយស្មារតីនេះ ផ្តល់របកគំហើញពីការសិក្សាស្ទង់មតិមូលដ្ឋាន[2] និងការសិក្សាវាយតម្លៃតាមបែបគុណភាព[3] របស់អង្គការ ឡេនដេសា( Ladnesa ) និងអង្គការដៃគូ ដែលបានអនុវត្តនៅក្នុងសហគមន៍នេសាទចំនួនប្រាំនៅក្នុងខេត្តកំពត និងខេត្តព្រះសីហនុ ដែលជាផ្នែកមួយនៃគម្រោងជីវភាព និងព្រៃកោងកាងនៅតំបន់ឆ្នេរ ដើម្បីបង្ហាញពីបញ្ហាវិសមភាពយេនឌ័រនៅក្នុងការគ្រប់គ្រងសហគមន៍នេសាទ រួមទាំងមូលហេតុ និងឫសគល់នៃវិសមភាពទាក់ទងនឹងបទដ្ឋានសង្គម និងជំនឿក្នុងតំបន់។ ឧបសគ្គដែលកំណត់ការចូលរួមរបស់ស្ត្រីនៅក្នុងសហគមន៍នេសាទ និងភាពជាអ្នកដឹកនាំកំពុងកំណត់ផងដែរនូវជីវភាពរស់នៅ សិទ្ធិលើធនធានធម្មជាតិ និងការរួមចំណែកក្នុងសកម្មភាពអាកាសធាតុ។ បទពិសោធន៍ស្រាវជ្រាវ និងគម្រោងនៅក្នុងសហគមន៍នេសាទទាំងប្រាំ ផ្តល់នូវការយល់ដឹងពី អន្តរាគមន៍ និងផ្លូវឆ្ពោះទៅរកប្រសិទ្ធភាពសម្រាប់ការពង្រឹងសហគមន៍នេសាទ តាមរយៈសមភាពយេនឌ័រ។

## វិធីសាស្ត្រស្រាវជ្រាវ

អង្គការដៃគូក្នុងស្រុករបស់ឡេនដេសា ( Landesa ) បានធ្វើការសិក្សាស្ទង់មតិមូលដ្ឋានក្នុងខែ វិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២៣ ជាមួយនឹងប្រជានេសាទចំនួន ២៣២នាក់ (ស្ត្រី ១១៨នាក់ និងបុរស ១១៤

---

[1] Chambon, M., Miñarro, S., Alvarez Fernandez, S. et al. 2024. A synthesis of women's participation in small-scale fisheries management: why women's voices matter. Rev Fish Biol Fisheries 34, 43–63. https://doi.org/10.1007/s11160-023-09806-2
[2] Landesa. 2024. Baseline survey report: Mangroves Asia – Cambodia. Phnom Penh, Cambodia: Landesa.
[3] Chrin, Bunsamkaneka. 2023. Background assessment report: Climate-mangrove conditions, community capacities, programmatic environment, and GESI considerations in the pilot sites, Lok Kresna. Phnom Penh, Cambodia: Landesa.
Chrin, Bunsamkaneka. 2023. Background assessment report: Climate-mangrove conditions, community capacities, programmatic environment, and GESI considerations in the pilot sites, MFMA. Phnom Penh, Cambodia: Landesa.

នាក់) ក្នុងសហគមន៍នេសាទចំនួនប្រាំ ។ យើងក៏បានធ្វើការសិក្សាវាយតម្លៃបែបគុណភាព រួមទាំងការសម្ភាសន៍អ្នកពាក់ព័ន្ធ និងការពិភាក្សាជាក្រុមផ្តោតលើយេនឌ័រ ដោយមានសមាជិកសហគមន៍នេសាទចំនួន ៥៩នាក់ និងអ្នកពាក់ព័ន្ធសំខាន់ៗ (ស្ត្រី ១៤នាក់ បុរស ៤៥នាក់) មកពីទូទាំងតំបន់ពាក់ព័ន្ធក្នុងគម្រោងក្នុងអំឡុងពីខែតុលា ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២៣។

សហគមន៍នេសាទទាំងប្រាំរួមមាន៖ សហគមន៍នេសាទកោះគ្រឹះស្នាលក ស្ថិតនៅក្នុងឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត។ សហគមន៍នេសាទបួនផ្សេងទៀតរួមមាន សហគមន៍នេសាទបន្ទាយប្រិយ៍, សហគមន៍នេសាទសំរុង, សហគមន៍នេសាទដំពូខ្មៅ, និងសហគមន៍នេសាទបឹងរាំង ស្ថិតនៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ (MFMA) ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

## យេនឌ័រ ការចិញ្ចឹមជីវិតនៅតំបន់ឆ្នេរ និងភាពធន់នឹងអាកាសធាតុ

ទោះបីជាការចិញ្ចឹមជីវិតដោយផ្អែកលើសហគមន៍នេសាទ មានសារៈសំខាន់សម្រាប់ទាំងស្ត្រី និងបុរសក៏ដោយ ជម្រើសនៃការចិញ្ចឹមជីវិតរបស់ស្ត្រី មិនសូវទទួលបានផលចំណេញ និងមានភាពធន់នឹងអាកាសធាតុដូចបុរសឡើយ។

- ការរកឃើញពីការស្ទង់មតិ និងការវាយតម្លៃបែបគុណភាពបង្ហាញថា ជីវភាពរស់នៅដែលពឹងផ្អែកលើធនធានសហគមន៍នេសាទគឺជា ផ្នែកមួយដ៏សំខាន់នៃការចិញ្ចឹមជីវិតរបស់ស្ត្រី និងបុរសនៅទូទាំងសហគមន៍។ ស្ត្រីជួយប្តីប្រមូលផលត្រី ឬក្តាមក្បែរព្រៃកោងកាង និងតំបន់សមុទ្រទឹករាក់ៗ។ ពួកគេក៏អាចចូលរួមក្នុងសកម្មភាពដូចជា បដិសណ្ឋារកិច្ចអេកូទេសចរណ៍ និងសកម្មភាពនេសាទក្រោយការប្រមូលផល (ឧទាហរណ៍ ការបែងចែកត្រីសម្រាប់លក់បន្ទាប់ពីចាប់បាន ការបកសាច់ក្តាម)។ ផ្ទុយទៅវិញ ក្រៅពីការនេសាទសមុទ្រទឹករាក់ បុរសក៏ប្រកបរបរនេសាទក្នុងសមុទ្រទឹកជ្រៅ ការធ្វើប្រតិបត្តិការនេសាទ និងប្រើប្រាស់ទូកធ្វើដំណើរទៅកាន់តំបន់នេសាទដែលនៅឆ្ងាយពីសហគមន៍។

- ជម្រើសនៃការចិញ្ចឹមជីវិតរបស់ស្ត្រីនៅក្នុងសហគមន៍នេសាទគឺ មានផលិតភាពទាបបំផុត ដោយសារតែហេដ្ឋារចនាសម្ព័ន្ធខ្សែសង្វាក់ផលិតកម្មមិនល្អ និងបញ្ហាប្រឈមទីផ្សារ ខណៈដែលបុរសមាន ទំនោររកប្រាក់បានច្រើនជាងស្ត្រី។
- បទដ្ឋានសង្គមដែលកំណត់ថា ការនេសាទគឺជា ការងារដែលមានគ្រោះថ្នាក់សម្រាប់ស្ត្រី និងស្ត្រីគ្រាន់តែជាអ្នកគាំទ្រសកម្មភាពនេសាទប៉ុណ្ណោះ និងមិនអាចចេញនេសាទដោយខ្លួនឯង បានដាក់កម្រិតជម្រើសសេដ្ឋកិច្ចរបស់ស្ត្រី។ នៅពេលដែលមានព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ បណ្តាល

ឱ្យបាត់បង់ព្រៃកោងកាង និងការរិចរិលប្រព័ន្ធអេកូឡូស៊ីសម្រាប់ការប្រកបរបរចិញ្ចឹមជីវិតនៅតំបន់ទឹកពាក់ ជាការឆ្លើយតប បុរសអាចប្ដូរទៅជាការនេសាទសមុទ្រទឹកជ្រៅបាន ប៉ុន្តែស្ត្រីមិនអាចធ្វើបាន។

## យេនឌ័រ និងការគ្រប់គ្រងសហគមន៍នេសាទ

របកគំហើញពីការវាយតម្លៃគុណភាព ក៏បង្ហាញផងដែរថា បទដ្ឋានសង្គម និងជំនឿរបស់សហគមន៍មូលដ្ឋាន រារាំងស្ត្រី ក្នុងមុខងារជាអ្នកតំណាងដ៏សំខាន់របស់ស្ត្រី និងក្នុងការចូលរួមសហគមន៍នេសាទ។

- បទដ្ឋានសង្គម ដែលថា បុរសគឺជា មេគ្រួសារតែមួយគត់ បានចាត់តាំងឱ្យបុរសក្លាយជាអ្នកដឹកនាំ និងដើរតួនាទីក្នុងការសម្រេចចិត្តនៅក្នុងសហគមន៍នេសាទ។ ដោយឡែក ស្ត្រីមានឱកាសតិចជាងបុរស ក្នុងការចូលរួមក្នុងកិច្ចប្រជុំ និងសកម្មភាពពាក់ព័ន្ធនានារបស់សហគមន៍នេសាទ ដែលកត្តានេះ កាន់តែកម្រិតដល់ការអនុញ្ញាតឱ្យស្ត្រីមានសំឡេងក្នុងការសម្រេចចិត្ត ដោយសារតែ ទំនួលខុសត្រូវថែទាំផ្ទះសម្បែង ស្វាមីមិនយល់ព្រមឱ្យភរិយាចូលរួមក្នុងការប្រជុំ ឬស្ត្រីមានអារម្មណ៍ថាមិនសូវមានសមត្ថភាពក្នុងការដឹកនាំដោយសារទទួលបានការអប់រំជាផ្លូវការតិចតួចជាងបុរស។
- អាស្រ័យហេតុនេះ ទោះបីជាអនុក្រឹត្យស្ដីពី ការគ្រប់គ្រងសហគមន៍នេសាទ ចែងថាស្ត្រីនឹងត្រូវបានលើកទឹកចិត្តឱ្យឈរឈ្មោះជាបេក្ខជន សម្រាប់ការបោះឆ្នោត នៅក្នុងគណៈកម្មការសហគមន៍នេសាទក៏ដោយ ក៏ចំនួនសមាជិកគណៈកម្មការជាស្ត្រី ក្នុងការអនុវត្តការងារ នៅមានតិចតួចនៅឡើយ។
- ជាងនេះទៅទៀត ក្នុងចំណោមស្ត្រីដែលធ្វើការជាគណៈកម្មការសហគមន៍នេសាទ ពួកគេភាគច្រើនមានទំនោរកាន់តួនាទីផ្នែករដ្ឋបាល និងការគ្រប់គ្រងហិរញ្ញវត្ថុប៉ុណ្ណោះ ហើយត្រូវបានរឹតត្បិតចំពោះមុខតំណែងជាអ្នកដឹកនាំ។
- ទំនួលខុសត្រូវបែបប្រពៃណីសម្រាប់ការថែទាំផ្ទះសម្បែង រួមមានការចម្អិនអាហារ ការងារសម្អាត ការថែទាំកូន និងការធានាសុខុមាលភាពទូទៅរបស់គ្រួសារ ធ្វើឱ្យស្ត្រីតែងតែចាត់ចែងការងាររបស់ពួកគេនៅផ្ទះ ក្នុងពេលជាមួយគ្នាដើម្បីបង្កើតប្រាក់ចំណូល។ អាស្រ័យហេតុនេះ ដើម្បីឱ្យស្ត្រីអាចចូលរួមក្នុងកិច្ចប្រជុំ និងសកម្មភាពគ្រប់គ្រងធនធានរបស់សហគមន៍នេសាទបាន លុះត្រាតែសកម្មភាពទាំងនោះ ត្រូវពាក់ព័ន្ធនឹងសកម្មភាពចិញ្ចឹមជីវិត ហើយមិនតម្រូវឱ្យស្ត្រីធ្វើដំណើរឆ្ងាយពីផ្ទះ។ ប្រសិនបើស្ត្រីទទួលបានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុពីកិច្ចការងារទាំងនោះ ស្វាមីរបស់ពួកគេ ក៏ទំនងជានឹងយល់ព្រមឱ្យពួកគេចូលរួមក្នុងសកម្មភាពនានារបស់សហគមន៍។

ការរឹតត្បិតក្នុងសង្គម និងចល័តភាព អាចរារាំងស្ត្រីមិនឱ្យទទួលបានព័ត៌មានពីការគ្រប់គ្រងសហគមន៍នេសាទប្រកបដោយប្រសិទ្ធភាព ជាពិសេសពីឱកាសរបស់ស្ត្រី ក្នុងការរួមចំណែកការគ្រប់គ្រង និងអភិបាលកិច្ចសហគមន៍នេសាទ។

- លទ្ធផលស្ទង់មតិបង្ហាញថា ស្ត្រីយល់អំពីច្បាប់ សម្រាប់ការរស់នៅ និងធ្វើការងារនៅក្នុងសហគមន៍នេសាទ។ ប៉ុន្តែ ស្ត្រីអាចមានចំណេះដឹងតិចតួចនៅឡើយ លើបញ្ហាទាក់ទងនឹងការគ្រប់គ្រងសហគមន៍នេសាទ ដូចជាបញ្ហាព្រំប្រទល់សហគមន៍នេសាទ និងការបំពានច្បាប់សហគមន៍នេសាទពីសំណាក់អ្នករស់នៅខាងក្រៅសហគមន៍។
- ឧទាហរណ៍ ការស្ទង់មតិរកឃើញថា មានសមាមាត្រស្ត្រីច្រើនជាងបុរស ដែលមិនបានដឹងអំពីបញ្ហាការបំពានច្បាប់សហគមន៍នេសាទ ពីសំណាក់អ្នករស់នៅខាងក្រៅសហគមន៍ រួមទាំងការបំពុលតំបន់ព្រៃកោងកាង (តាមរយៈវារីវប្បកម្ម/កាកសំណល់ឧស្សាហកម្មឯកជន ឬមកពីមូលហេតុផ្សេងទៀត) ការនេសាទខុសច្បាប់ និងការកាប់ព្រៃកោងកាង។
- កង្វះខាតព័ត៌មានសម្រាប់ស្ត្រី អាចបណ្តាលមកពី ចល័តភាពរបស់ពួកគេនៅមានកម្រិត ហើយស្ត្រីមានឱកាសតិចតួច ក្នុងការចូលរួមកិច្ចប្រជុំ និងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀតជាមួយអ្នកដទៃនៅទូទាំងសហគមន៍នេសាទ។

## ស្ត្រី និង ការស្តារនិងអភិរក្សព្រៃកោងកាង

របកគំហើញផ្សេងៗទៀតពីតំបន់អាស៊ីអាគ្នេយ៍ បង្ហាញថាការគាំទ្រនូវតួនាទីរបស់ស្ត្រីក្នុងការគ្រប់គ្រងព្រៃកោងកាង រួមទាំងការស្តារ និងការអភិរក្ស អាចជួយលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង និងការអភិវឌ្ឍជីវភាពរស់នៅរបស់ស្ត្រីឱ្យបានប្រសើរ ។

- ដោយមានការគាំទ្រពីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល សហភាពស្ត្រីនៅស្រុកទៀនឡាំង (Tien Lang) ប្រទេសវៀតណាម បានដើរតួនាទីយ៉ាងសំខាន់ក្នុងការដាំព្រៃកោងកាង និងការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ពី អត្ថប្រយោជន៍ច្រើនយ៉ាងនៃព្រៃកោងកាង។[4] ជំនាញដែលពួកគេទទួលបានក្នុងការដាំព្រៃកោងកាង ក៏បានជួយសម្រួលដល់ការចូលរួមរបស់ពួកគេនៅក្នុងអាជីវកម្មបណ្តុះកូនឈើផងដែរ។
- ការបណ្តុះបណ្តាលឱ្យមានការយល់ដឹង អំពីយេនឌ័រទូទាំងសហគមន៍ រួមជាមួយនឹងអន្តរាគមន៍បន្ថែម ដើម្បីលើកកម្ពស់ការចូលរួមដ៏សំខាន់របស់ស្ត្រី នៅក្នុងគម្រោងស្តារព្រៃកោងកាងអេកូឡូស៊ីតាមបែបសហគមន៍នៅខេត្តស៊ូឡាវេស៊ី ខាងត្បូង (South Sulawesi) នៃប្រទេសឥណ្ឌូនេស៊ី បាន

[4] USAID. 2017. Why gender matters in sustainable coastal resource management within Vietnam's mangrove forests. Our Coast Our Future Pilot Brief no. 1.

នាំទៅរកការបង្កើតក្រុមស្ត្រីកោងកាង (Womangrove) ដែលក្រុមនេះមានឱកាសចូលរួមក្នុងការសម្រេចចិត្តលើការប្រើប្រាស់ និងគ្រប់គ្រងធនធានព្រៃកោងកាងនៅថ្នាក់មូលដ្ឋាន។[5]

- គម្រោងលើកកម្ពស់ជលផល ធនធានតំបន់ឆ្នេរ និងជីវភាព នៅក្នុងប្រទេសហ្វីលីពីន បានគាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រី នៅក្នុងក្រុមល្បាតសមុទ្រ និងលើកកម្ពស់ការអភិវឌ្ឍជីវភាពរបស់ស្ត្រីនៅក្នុងសាលាធុរកិច្ចផ្អែកលើវារីវប្បកម្ម។[6] អ្នកចូលរួមជាស្ត្រី បានរៀនពីរបៀបបន្ថែមតម្លៃដល់ផលិតផលសារ៉ាយសមុទ្រក្នុងស្រុក បានវិនិយោគក្នុងមជ្ឈមណ្ឌលកែច្នៃ និងបានដាំព្រៃកោងកាងដើម្បីការពារតំបន់ឆ្នេរប្រឆាំងនឹងការខូចខាតដោយព្យុះ។
- ក្នុងចំណោមអន្តរាគមន៍ផ្សេងៗទៀត គម្រោងជីវភាព និងព្រៃកោងកាងនៅតំបន់ឆ្នេររបស់អង្គការឡេនដេសា (Landesa) នៅកម្ពុជា ផ្តោតសំខាន់លើការបណ្តុះបណ្តាលពីសមធម៌យេនឌ័រសម្រាប់ស្ត្រី និងបុរសជាសមាជិកសហគមន៍នេសាទ ពីរបៀបគ្រប់គ្រងការបណ្តុះ និងដាំដើមកោងកាង ដើម្បីគាំទ្រ និងលើកកម្ពស់តួនាទីរបស់ស្ត្រី ក្នុងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងប្រកបដោយភាពឆ្លាតវៃ។

## យេនឌ័រ និងគម្រោងជីវភាព និងព្រៃកោងកាងនៅតំបន់ឆ្នេរ ដឹកនាំដោយអង្គការ ឡេនដេសា (Landesa)

គម្រោងជីវភាព និងព្រៃកោងកាងនៅតំបន់ឆ្នេរ ដែលដឹកនាំដោយអង្គការ ឡេនដេសា (Landesa) រួមបញ្ចូលនូវ កិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អសមធម៌នៃអភិបាលកិច្ចសហគមន៍នេសាទ តាមរយៈការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី ជំនាញតស៊ូមតិ និងបំនិននិយាយជាសាធារណៈ។ ឧទាហរណ៍ គម្រោងនេះជួយសម្រួលផ្តល់ឱកាសក្នុងការបង្កើតបណ្តាញទំនាក់ទំនង សម្រាប់សមាជិកសហគមន៍នេសាទជាស្ត្រី ដើម្បីលើកកម្ពស់ដល់អន្តរកម្មរបស់ពួកគេ ជាមួយស្ត្រីមកពីសហគមន៍នេសាទផ្សេងៗទៀត ពង្រឹងការយល់ដឹងរបស់ពួកគេអំពី សារៈសំខាន់របស់សហគមន៍នេសាទ និងជំរុញស្មារតីសាមគ្គីភាព និងភាពជាសហគមន៍ ក្នុងចំណោមបណ្តាស្ត្រី។ ក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ គម្រោងបានគាំទ្រដល់សមាជិកសហគមន៍នេសាទជាស្ត្រីចំនួន ១៥០នាក់ ដើម្បីចូលរួមក្នុងកិច្ចប្រជុំបណ្តាញ និងព្រឹត្តិការណ៍នានារបស់សហគមន៍នេសាទ នៅថ្នាក់ស្រុក និងថ្នាក់ខេត្ត នៅក្នុងខេត្តព្រះសីហនុ។ គម្រោង

---

[5] Brown, B., Fadillah, R., Nurdin, Y., Soulsby, I., & Ahmad, R. 2014. Case study: Community based ecological mangrove rehabilitation (CBEMR) in Indonesia. *S.A.P.I.E.N.S, 7*(2). Retrieved from http://sapiens.revues.org/1589

[6] IFAD. 2022. Women-led sea patrols in the Philippines are protecting livelihoods and the ocean. Retrieved from https://www.ifad.org/en/w/rural-voices/women-led-sea-patrols-in-the-philippines-are-protecting-livelihoods-and-the-ocean

នេះក៏ផ្តល់ការពង្រឹងសមត្ថភាពដល់ស្ត្រី និងបុរសជាសមាជិកសហគមន៍នេសាទ លើការគ្រប់គ្រងបណ្តុះកូនកោងកាង និងការដាំដើមកោងកាងឡើងវិញ និងធ្វើការជាមួយសមាជិកសហគមន៍ ដើម្បីកំណត់ជម្រើសនៃការវិនិយោគចិញ្ចឹមជីវិតដែលអាចអនុវត្តបានផងដែរ។

## សេចក្តីសន្និដ្ឋាន

របកគំហើញពីការស្រាវជ្រាវនៅសហគមន៍នេសាទទាំងប្រាំដែលស្ថិតនៅក្នុងខេត្តកំពត និងខេត្តព្រះសីហនុបង្ហាញថា ស្ត្រីនៅក្នុងសហគមន៍នេសាទ ជារឿយៗមានជម្រើសក្នុងការចិញ្ចឹមជីវិតតិចជាងបុរស ដោយសារបទដ្ឋានសង្គមដែលបានកំណត់នូវសកម្មភាពសេដ្ឋកិច្ចសមស្របតាមបែបយេនឌ័រ។ ផ្នត់គំនិតសង្គមរឹតត្បិត បានរារាំងសមត្ថភាពរបស់ស្ត្រីក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងស្វែងរកឱកាសធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈជីវភាពរស់នៅដោយផ្អែកលើសហគមន៍នេសាទនាពេលបច្ចុប្បន្ន។

ការរួមចំណែករបស់ស្ត្រីចំពោះការគ្រប់គ្រង និងការចូលរួមនៅក្នុងសហគមន៍នេសាទ ត្រូវបានរឹតបន្តឹង ដោយសារ វប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីនៅក្នុងសង្គម ដែលកំណត់នូវតួនាទីរបស់ស្ត្រី និងបុរស។ ស្ត្រីក៏ខ្វះនូវព័ត៌មានសំខាន់ៗសម្រាប់ការគ្រប់គ្រងសហគមន៍នេសាទ ពាក់ព័ន្ធនឹងព្រំប្រទល់របស់សហគមន៍នេសាទ និងការរំលោភបំពានលើបទបញ្ញត្តិរបស់សហគមន៍ពីសំណាក់អ្នកដែលមិនមែនជាសមាជិក ។

ការគាំទ្រតួនាទីរបស់ស្ត្រីក្នុងការគ្រប់គ្រងព្រៃកោងកាង អាចជួយលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងបាន។ កិច្ចខិតខំប្រឹងប្រែងបែបនេះ ទាមទារឱ្យមានការសម្របសម្រួលក្នុងការផ្តល់ឱកាសដល់ស្ត្រី ឱ្យបានចូលរួមក្នុងការស្តារឡើងវិញ និងការអភិរក្សព្រៃកោងកាង និងទាមទារឱ្យមានការលើកកម្ពស់ការអភិវឌ្ឍជីវភាពរស់នៅប្រកបដោយចីរភាព ដែលស្របតាមតម្រូវការ និងចំណង់ចំណូលចិត្តរបស់ស្ត្រី។

## សំណូមពរ៖

ដើម្បីបង្កើតសហគមន៍នេសាទប្រកបដោយសមធម៌ បរិយាប័ន្ន និងនិរន្តរភាព ដែលផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងដោះស្រាយរាល់ឧបសគ្គ ដែលរារាំងស្ត្រីនៅក្នុងតំបន់គោលដៅពីការចូលរួមយ៉ាងពេញលេញ រដ្ឋាភិបាល និងបណ្តាភាគីពាក់ព័ន្ធនានា អាចចាត់វិធានការដូចខាងក្រោម៖

- លើកកម្ពស់ជម្រើសជីវភាពរស់នៅដែលអាចរកប្រាក់ចំណេញបានកាន់តែច្រើនសម្រាប់ស្ត្រី រួមបញ្ចូលទាំងការបណ្តុះបណ្តាលជំនាញ ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការទទួលបានទីផ្សារ។
- បង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងការគ្រប់គ្រងសហគមន៍នេសាទ តាមរយៈវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ការគាំទ្រពីមិត្តភក្តិ ជើងឯកបុរស និងស្ត្រី និងយុទ្ធសាស្ត្រផ្សេងៗ

ជាច្រើនទៀត ដើម្បីយកឈ្នះផ្នត់គំនិតសង្គមដែលរើសអើងយេនឌ័រ។ គួរលើកកម្ពស់ការទទួលស្គាល់របស់សហគមន៍នេសាទនៅតំបន់ឆ្នេរ ចំពោះតម្លៃការងាររបស់ស្ត្រីនៅក្នុងវិស័យជលផលរាប់ចាប់តាំងពីដំណាក់កាលមុន រហូតដល់ដំណាក់ក្រោយការប្រមូលផលនេសាទផងដែរ។

- កសាងសមត្ថភាព និងចំណេះដឹង ក្នុងចំណោមសមាជិកសហគមន៍នេសាទ ជាពិសេសស្ត្រី អំពីរបៀបតាមដាន វិភាគ និងរាយការណ៍ មូលហេតុ និងស្ថានភាពនៃការវិចរិលធនធាននៅក្នុងសហគមន៍នេសាទ តាមរយៈសកម្មភាពនានាដូចជា ការស្រាវជ្រាវសហគមន៍ និងសារព័ត៌មាន ដើម្បីឱ្យស្ត្រី និងបុរសបានចូលរួមស្មើភាពគ្នា ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងអភិបាលកិច្ចរបស់សហគមន៍នេសាទ។
- លើកកម្ពស់ការបញ្ជ្រាបយេនឌ័រនៅក្នុងបណ្តាគោលនយោបាយ និងបទបញ្ញត្តិជលផលនានា៖ ទាំងនេះរួមបញ្ចូលនូវ ការធានាឱ្យបាននូវបទបញ្ញត្តិសមភាពយេនឌ័រ នៅក្នុងអនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ការកំណត់កូតាសម្រាប់ស្ត្រីនៅក្នុងគណៈកម្មការសហគមន៍នេសាទ និងមុខតំណែងក្នុងភាពជាអ្នកដឹកនាំ និងការបង្កើតផែនការគ្រប់គ្រង និងប្រព័ន្ធត្រួតពិនិត្យដែលឆ្លើយតបទៅនឹងយេនឌ័រ។
- ដាក់បញ្ចូលនូវបណ្តាគោលការណ៍សមធម៌យេនឌ័រនានា នៅក្នុងក្របខណ្ឌច្បាប់ជលផល ដូចជាតាមរយៈការធ្វើវិសោធនកម្មច្បាប់ជលផល ដោយតម្រូវឱ្យមានការអនុវត្តឆ្លើយតបទៅនឹងយេនឌ័រ ការបែងចែកមូលនិធិសម្រាប់សមភាពយេនឌ័រ និងការតាមដានការអនុវត្តនូវសមធម៌យេនឌ័រនៅក្នុងគោលនយោបាយ និងកម្មវិធីនានា ដោយការរៀបចំការចុះជួបផ្ទាល់នៅមូលដ្ឋាន ឬសកម្មភាពប្រមូលទិន្នន័យផ្សេងៗទៀត។